- តាមដាន ស្រាវជ្រាវ និងប្រមូលព័ត៌មានទាក់ទងនឹងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មានផ្សេងៗ
- ចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធនានា ដើម្បីទទួលបាននូវព័ត៌មានទាក់ទងនឹងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- **ចូលរួមក្នុងកិច្ចប្រជុំ វេទិកា និងវគ្គបណ្តុះបណ្តាលជំនាញនានា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការចូលរួមសាធារណៈ**
- រៀបចំ គ្រប់គ្រង និងបញ្ចូលទិន្នន័យរបស់នាយកដ្ឋាននៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមនានារបស់ក្រសួង
- រៀបចំផែនការការងារ និងរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និង ប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំនាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋាន។

## ៣.៤ ការចូលរួមរបស់សាធារណជន

| ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ | ដំណាក់កាលទី៤ |
|---|---|---|---|
| ការជួបសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងពាក់ព័ន្ធ | កិច្ចប្រជុំពិគ្រោះយោបល់ជាក្រុមជាមួយប្រជាពលរដ្ឋ | កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ទីរ-ស្ថាប័នពាក់ព័ន្ធ | សិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលពិគ្រោះយោបល់ថ្នាក់ខេត្ត |

## ៣.៥ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៥៥.**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងកិច្ចការពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាង និងអនុវត្តន៍គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រផែនការសកម្មភាពផែនការថវិកាគោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំនិងអនុវត្តន៍វិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងការពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- **ពិនិត្យ វិភាគ និងវាយតម្លៃសម្រាប់កំណត់ទីតាំងគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន**
- ពិនិត្យ និងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន



- កំណត់លក្ខខណ្ឌការងារ និងគោលការណ៍បច្ចេកទេសសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង កិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានជាមួយម្ចាស់គម្រោង ដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម
- **ពិនិត្យ និងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬពេញលេញនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**
- **ពិនិត្យ និងរៀបចំកិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន**
- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- **ជំរុញការអនុវត្តការបង់សេវាការងារសាធារណៈ មូលនិធិទាយជ្ជទានបរិស្ថាន និងថវិកាពិន័យអន្តរការណ៍**
- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តការប្រមូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម
- គ្រប់គ្រងទទួលខុសត្រូវនិងសម្របសម្រួលការងាររដ្ឋបាលបុគ្គលិកហិរញ្ញវត្ថុគណនេយ្យ ផែនការថវិការយៈពេលខ្លីមធ្យម និងវែង និងអង្កេតតាមដានការងារផ្ទៃក្នុងរបស់នាយកដ្ឋាន
- **ជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជន និងការទទួលបានព័ត៌មាននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**
- កំណត់នីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- សម្របសម្រួលការងារជាមួយបណ្តាអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថានអង្គភាពពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញការងារវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដល់អង្គភាពថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍ និងភាគីពាក់ព័ន្ធ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងបរិស្ថាន

# ការចូលរួមជាសាធារណៈក្នុងនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ១. និយមន័យ

**ការចូលរួមពីសាធារណជន៖** គឺជាការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍន៍ រួមមាន ក្រសួង/ស្ថាប័នអាជ្ញាធរមូលដ្ឋានមន្ទីរពាក់ព័ន្ធ ម្ចាស់គម្រោងក្រុមហ៊ុនទីប្រឹក្សាតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការពាក់ព័ន្ធតំបន់គម្រោង។






រៀបចំដោយ

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ២. គោលបំណង

ការចូលរួមពីសាធារណជន និងស្ថាប័នពាក់ព័ន្ធនេះគឺដើម្បីបង្ហាញពីព័ត៌មានលម្អិតរបស់គម្រោងក៏ដូចជាការទទួលយកនូវការព្រួយបារម្ភ មតិរិះគន់ កែលម្អ យោបល់គាំទ្រ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោង។

## ៣. បទដ្ឋាន គតិយុត្តពាក់ព័ន្ធ

### ៣.១ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ១._**

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- **បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង**

### ៣.២ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន





**មាត្រា ៥៥ តួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តផែនការ និងថវិកាលើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធកសាងសមត្ថភាពមន្ត្រីនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានាដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋានរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចសន្យាការពារបរិស្ថាន ដោយសម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំ និងអនុវត្តន៍វិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងការត្រួតពិនិត្យលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំឯកសារស្តីពីគោលការណ៍ណែនាំ និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ និងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- **ធានានូវការទទួលបានព័ត៌មាន និងជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**
- ពិនិត្យ និងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង និងលក្ខខណ្ឌការងារគម្រោងដើម្បីកំណត់អំពីតម្រូវការសម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន កំណត់លក្ខខណ្ឌសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម
- ជំរុញការអនុវត្តការបង់មូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម
- សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីចុះអង្កេតតាមដាន និងពង្រឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចសន្យាការពារបរិស្ថាន
- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងសាធារណៈនិងគម្រោងវិនិយោគឯកជន



- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

### ៣.៣ ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន

**ប្រការ២._**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានមាន ១០ (ដប់) ការិយាល័យដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យនីតិកម្ម
- ការិយាល័យស្រាវជ្រាវ និងបណ្តុះបណ្តាល
- **ការិយាល័យចូលរួមសាធារណៈ**
- ការិយាល័យពិនិត្យគម្រោងឧស្សាហកម្ម និងសុខាភិបាល
- ការិយាល័យពិនិត្យគម្រោងរ៉ែ និងថាមពល
- ការិយាល័យពិនិត្យគម្រោងកសិកម្ម និងធនធានទឹក
- ការិយាល័យពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍
- ការិយាល័យពិនិត្យអង្កេតតាមដាន
- ការិយាល័យមូលនិធិបរិស្ថាន និងសង្គម។

**ប្រការ៦._**

**ការិយាល័យចូលរួមសាធារណៈ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖**

- **ផ្តួចផ្តើមរៀបចំលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងគោលការណ៍ណែនាំស្តីពីការចូលរួមជ សាធារណៈ**
- ធានានូវការទទួលបានព័ត៌មាន និងជំរុញឱ្យមានការចូលរួមជាប្រចាំរបស់ សាធារណជននៅក្នុងដំណាក់កាលចំណាត់ថ្នាក់គម្រោង កំណត់វិសាលភាពគម្រោង ពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអង្កេតតាមដានគម្រោង
- ចុះអង្កេតការងាររបស់ក្រុមហ៊ុនទីប្រឹក្សា នៅក្នុងដំណាក់កាលផ្សព្វផ្សាយគម្រោង អភិវឌ្ឍន៍ ការសិក្សាស្រាវជ្រាវ និងការពិគ្រោះយោបល់លើរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅថ្នាក់រាជធានី ខេត្ត
- **ផ្តល់យោបល់ពីការចូលរួមជាសាធារណៈទាក់ទងនឹងរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម**
- **បំផុស និងជំរុញដល់សាធារណៈក្នុងការផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេ ប៉ះពាល់បរិស្ថាន និងសង្គម**
- ផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាធារណជនទូទៅលើកា រង អង្កេតតាមដានគម្រោងអភិវឌ្ឍន៍ដើម្បីចូលរួមផ្តល់យោបល់
- **ពន្យល់ និងបកស្រាយដល់សាធារណជនលើដំណើរការពិគ្រោះយោបល់ជាសាធារណៈ**